CITY OF LONG BEACH

# PRESS RELEASE

**សេចក្តីប្រកាសពត៌មាន**

ថ្ងៃអង្គារ  ទី ២៥ ខែសីហា  ឆ្នាំ ២០២០
ទំនាក់ទំនង៖ ស៊ីនធៀ បូធីស្តា  (Cynthia Bautista)
បណ្ណាធិការផ្នែកសេវាកម្មសំរាប់យុវជន និងក្រុមគ្រួសារ
ប្រចាំបណ្ណាល័យក្រុងឡុងប៊ិច
ទូរស័ព្ទ៖ 562-570-6645
អ៊ីម៉ែល ៖ Cynthia.Bautista@lbpl.org

សំរាប់ការចេញផ្សាយបន្ទាន់

# បណ្ណាល័យក្រុងឡុងប៊ិចសូមផ្តល់ជូនកម្មវិធីផ្តល់ចំណេះដឹងចំពោះកុមារ តាមប្រព័ន្ធអនឡាញ

ទីក្រុងឡុងប៊ិច  រដ្ឋកាលីហ្វរញ៉ា - បណ្ណាល័យក្រុងឡុងប៊ិច (Long Beach Public Library - LBPL) កំពុងបើកដំណើការកម្មវិធី “ជំរុញការអាន” (Dive into Reading) តាមប្រព័ន្ធអនឡាញ ដែល នេះជាផ្នែកមួយនៃកម្មវិធីផ្តល់ចំណេះដឹងចំពោះកុមារ  ។
កម្មវិធីនេះនឹងចាប់ផ្តើមការផ្សាយ ផ្ទាល់នៅលើទំព័រហ្វេសប៊ុករបស់បណ្ណាល័យក្រុងឡុងប៊ិច នៅថ្ងៃសៅរ៍ ទី២៩ ខែសីហា ឆ្នាំ២០២០ នេះ វេលាម៉ោង 10:30 នាទី ព្រឹក។

កម្មវិធី “ជំរុញការអាន” ជាយុទ្ធនាការមួយនៃកម្មវិធីផ្តល់ចំណេះដឹងរបស់បណ្ណាល័យ ចំពោះក្រុម គ្រួសារ ដែលមានកុមារមានអាយុ ៥ឆ្នាំ និងតិចជាងនេះ
ក្នុងការជំរុញអោយក្រុមគ្រួសារ ចូលរួម អានសៀវភៅរួមគ្នា ជាសរុបចំនួន១០០០ ក្បាល មុនពេលដែលកូនរបស់ពួកគេចូលបឋមសិក្សា។
ក្រុមគ្រួសារនឹងអាចតាមដានការវិវឌ្ឍន៍របស់ខ្លួន តាមរយៈប្រព័ន្ធការអានមួយឈ្មោះថា Beanstack ។

លោក រ៉ូប៊ើត ហ្គាសៀរ ដែលជាអភិបាលក្រុងឡុងប៊ិចបានមានប្រសាសន៍ថា៖
“កំឡុងពេលដែល ការសិក្សាបានផ្លាស់ប្តូរទៅប្រព័ន្ធអនឡាញក្នុងពេលមានជំងឺរាតត្បាតនេះ បណ្ណាល័យសាធារណៈ របស់យើងបានបំផ្លែងការរៀនអានឲ្យកាន់តែមានភាពទាក់ទាញ ដោយផ្តល់ជូនតាមប្រព័ន្ធ អនឡាញក្រោមបែបសកម្មភាព
សំរាប់កម្មវិធីផ្តល់ចំណេះដឹងដំបូង។ ខ្ញុំមានការសប្បាយរីករាយ
ដែលបានឃើញកម្មវិធីនេះដំណើការ នៅពេលដែលបណ្ណាល័យបន្តការបិទទ្វា
ក្នុងពេលមានវិបត្តិ សុខភាពសាធារណៈនេះ។

កម្មវិធី “ជំរុញការអាន”  ជាកម្មវិធីប្រកួតប្រជែងតាមពេលវេលាដែលខ្លួនមាន
ហើយក្រុមគ្រួសារ អាចឈ្នះរង្វាន់ និងអាចចូលរួមក្នុងកម្មវិធីដែលមានលក្ខណៈសិក្សា
ក្នុងពេលដែលអាចសម្រេច គោលដៅ ១០០០ ក្បាលបាន ។
ចាប់តាំងពីការចាប់ផ្តើមកម្មវិធីនេះពីខែ មេសា ឆ្នាំ ២០១៨ មក

ក្រោមការឧបត្ថម្ភពីមូលនិធិបណ្ណាល័យក្រុង (LBPL Foundation) គ្រួសារចំនួន ៧៣៦ បានចូល រួមក្នុងកម្មវិធីនេះ ហើយគ្រួសារចំនួន ៥៦ បានបញ្ចប់ការប្រកួតនេះ។

លោកស្រី គ្លេនដា វីលលៀមស៍ (Glenda Williams) ដែលជាប្រធានផ្នែកសេវាកម្មរបស់បណ្ណាល័យ បានមានប្រសាសន៍ថា៖ “គោលបំណងនៃយុទ្ធនាការ “ជំរុញការអាន” នេះគឺបណ្តុះជំនាញចំណេះ ដឹង ដំបូង សំរាប់អោយកុមារត្រៀមខ្លួនជាស្រេចក្នុងការចូលបឋមសិក្សា។ ការអានរួមគ្នា អាច ជួយបង្កើនចំណងរវាង មាតាបិតា និងកុមារ បង្កើតភាពជឿជាក់ និងបទពិសោធន៍ជាវិជ្ជមាន សំរាប់ការរៀនសូត្ររបស់ពួកគេ តរទៅថ្ងៃមុខ។

ការចាប់ផ្តើមផ្សាយកម្មវិធី “ជំរុញការអាន” នៅថ្ងៃសៅរ៍នេះនឹងរួមមានការបង្ហាញពីការធ្វើរបស់ ដោយខ្លួនឯង និងការច្រៀង ពីសំណាក់អ្នកចំរៀង និងអ្នកនិពន្ធបទភ្លេង ពីរភាសា ឈ្មោះ ណាថាលៀ (Nathalia)។ កុមារអាចចូលរួមធ្វើជាមួយបាន ដោយអាចទៅយកឧបករណ៍ទាំងនោះ បានដោយឥតគិតថ្លៃនៅបណ្ណាល័យ ប៊ីលីជីនឃីង (Billie Jean King Main Library អាសយដ្ឋាន 200 W. Broadway) ពីថ្ងៃទី ២៥ ដល់ថ្ងៃសៅរ៍ ទី ២៩ ពីម៉ោង ១០ ព្រឹក ដល់ម៉ោង ៣ រសៀល រហូតដល់ឧបករណ៍អស់ពី ស្តុក។ ការទៅយកឧបករណ៍នេះ នឹងធ្វើឡើងនៅក្រៅបណ្ណាល័យ ជិត ច្រកចូលធំ ដោយគោរពតាមគោលការណ៍នៅឃ្លាតពីគ្នា និងតម្រូវអោយមានការពាក់ម៉ាស ។

ចំពោះគ្រួសារដែលមានចំណាប់អារម្មណ៍ អាចចុះឈ្មោះនៅក្នុងគេហទំព័រ longbeach.beanstack.org ។ ចំពោះអ្នកដែលមានឈ្មោះនៅក្នុងកម្មវិធីរួចហើយ គួរចូលទៅក្នុង គេហទំព័រនោះផងដែរដើម្បីចុះឈ្មោះចូលកម្មវិធីអនឡាញ។ សំរាប់ព័ត៌មានបន្ថែម ចំពោះកម្មវិធី នេះ ឬកម្មវិធី និងសេវានានារបស់បណ្ណាល័យ ពលរដ្ឋអាចចូលទៅគេហទំព័ររបស់បណ្ណាល័យ www.lbpl.org ឬទូរស័ព្ទទៅលេខ (562) 570-7500 ពីថ្ងៃអង្គារ ដល់ថ្ងៃសៅរ៍ ពីម៉ោង ១០ ព្រឹក ដល់ ម៉ោង ៥ ល្ងាច។

ចាប់តាំងពីមានជំងឺរាតត្បាតកូវីដ-19 មក បណ្ណាល័យក្រុងឡុងប៊ិចបានបន្តបំរើពលរដ្ឋក្នុង ទីក្រុងឡុងប៊ិច តាមប្រព័ន្ធអនឡាញ ដោយផ្តល់ជូនជាសៀវភៅអេឡិកត្រូនិក និង សៀវភៅ ដែលអានអោយស្តាប់ ធនធានហ្វឹកហាត់ការងារ ជំនួយមេរៀន ការនិទានរឿងតាមអនឡាញ និងវីដេអូអំពីការរៀនផ្ទុំវត្ថុ។

សម្រាប់ពត៌មានថ្មីៗអំពី កូវីដ-19 និងពត៌មានលម្អិតដែលសាលាក្រុងឡុងប៊ិចកំពុងបំពេញ ការងារ ជួយដល់ពលរដ្ឋ សូមចូលទៅគេហទំព័រ longbeach.gov/COVID19 និងតាមយើងខ្ញុំ លើទំព័រ Facebook Twitter និង Instagram តាមរយៈ @LongBeachCity ។

###